អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ២១/២៣ ចេញផ្សាយ ខែកញ្ញា ឆ្នាំ២០២៣

## តួនាទីភារកិច្ចរបស់បុគ្គលទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការ

បុគ្គលទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការ គឺជាបុគ្គលស្នូលនៅក្នុងអង្គភាព ដែលត្រូវទទួលបន្ទុករៀបចំសម្របសម្រួលលើកិច្ចការនៃការគ្រប់គ្រងប្រតិបត្តិការរបស់អង្គភាព។ បន្ថែមពីនេះ បុគ្គលទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការត្រូវត្រួតពិនិត្យការងារតាមផ្នែកដែលខ្លួនទទួលបន្ទុកនៅក្នុងអង្គភាពគឺដើម្បីធានាបាននូវប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃក្នុងការអនុវត្តការងាររបស់មន្ត្រី។ ដូចនេះដើម្បីធានានូវប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃក្នុងការគ្រប់គ្រងប្រតិបត្តិការ បុគ្គលទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការមានភារកិច្ចធំៗ ចំនួន៤ គឺ÷

### ១) ការរៀបចំផែនការ

ការរៀបចំផែនការជាការងារចម្បងមួយរបស់បុគ្គលទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការដែលតម្រូវឱ្យកំណត់សកម្មភាពការងារលម្អិត និងការប្រើប្រាស់ធនធានសមស្របដើម្បីសម្រេចគោលដៅ និងគោលបំណងរបស់អង្គភាពទៅតាមពេលវេលាជាក់លាក់មួយ ដូចនេះ បុគ្គលទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការត្រូវរៀបចំផែនការឱ្យបានល្អតាមរយៈការកំណត់អំពីសូចនាករ និងលទ្ធផលរំពឹងទុកឱ្យបានច្បាស់លាស់ដើម្បីជួយដល់មន្ត្រីទទួលបន្ទុកអនុវត្តការងារអាចអនុវត្តការងារប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃ។




### ២) ការរៀបចំបែងចែកការងារ និងចាត់ចែងមន្ត្រីទទួលបន្ទុកអនុវត្តការងារ

បុគ្គលទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការ ត្រូវរៀបចំចាត់ចែងមន្ត្រីទទួលបន្ទុកអនុវត្តការងារនីមួយៗ ឱ្យបានច្បាស់លាស់ ដើម្បីអាចសម្រេចកម្មវិធីការងារទៅតាមផែនការដែលបានដាក់ចេញ។ ដូចនេះ បុគ្គលទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការ ត្រូវរៀបចំបែងចែកការងារ និងចាត់ចែងមន្ត្រីទទួលបន្ទុកអនុវត្តការងារឱ្យសមស្របទៅនឹងចំណេះ ជំនាញ និងបទពិសោធន៍ការងាររបស់មន្ត្រី ដើម្បីធានាបានប្រសិទ្ធភាពនៃការអនុវត្តការងាររបស់មន្ត្រី និងដើម្បីសម្រេចបាននូវរាល់គោលដៅដែលមានកំណត់ក្នុងផែនការ។




### ៣) ការសម្របសម្រួល និងតាមដានត្រួត-ពិនិត្យជាប្រចាំ

បុគ្គលទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការ ត្រូវធ្វើការសម្របសម្រួល និងតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្តការងាររបស់មន្ត្រី តាមរយៈការណែនាំ និងការផ្តល់មតិកែលម្អទៅលើការងារដែលត្រូវបានអនុវត្តដោយមន្ត្រីទទួលបន្ទុកអនុវត្តការងារ ដោយត្រូវប្រាកដថា មន្ត្រីទទួលបន្ទុកអនុវត្តការងារបានអនុវត្តទៅតាមផែនការ និងនីតិវិធីប្រតិបត្តិស្តង់ដាររបស់អង្គភាព ដើម្បីធានាឱ្យបានថាការអនុវត្តការងាររបស់មន្ត្រីទទួលបន្ទុកអនុវត្តការងារ សម្រេចបានទៅតាមលទ្ធផលរំពឹងទុកប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃ។ ក្នុងករណីការអនុវត្តរបស់មន្ត្រីទទួលបន្ទុកអនុវត្តការងារពុំទាន់បានល្អនៅឡើយ បុគ្គលទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការអាចផ្តល់មតិកែលម្អ និងផ្តល់ការណែនាំបន្ថែម ដើម្បីធានាថាមន្ត្រីទទួលបន្ទុកអនុវត្តការងារទៅតាមផែនការ និងតាមនីតិវិធីប្រតិបត្តិការ។



### ៤) ការវាយតម្លៃការអនុវត្តការងាររបស់មន្ត្រីទទួលបន្ទុកការងារ និងផែនការដែលបានដាក់ចេញ

បុគ្គលទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការ ត្រូវធ្វើការវាយតម្លៃទៅលើការអនុវត្តការងាររបស់មន្ត្រីទទួលបន្ទុកអនុវត្តការងារទៅនឹងផែនការដែលបានដាក់ចេញ ដោយធ្វើការវាស់វែងវាយតម្លៃនូវរាល់សកម្មភាពការងារទាំងអស់របស់មន្ត្រីទទួលបន្ទុកអនុវត្តការងារ ១) ទៅលើការអនុវត្តប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃ ២) មន្ត្រីបានអនុវត្តការងារទៅតាមយន្តការ ឬនីតិវិធីប្រតិបត្តិការងារស្តង់ដាររបស់អង្គភាព និង៣) ការអនុវត្តនោះបានសម្រេចនូវគោលដៅរបស់អង្គភាព។



**អត្ថបទ៖ លោក ជឿន វណ្ណារិទ្ធិ**

**ឯកសារយោង៖**

១. ឧត្តមានុវត្តន៍នៃការគ្រប់គ្រងប្រតិបត្តិការរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**